ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខៈ ១៥៤១ សសរ.... សក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧...ខែ កញ្ញា...ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលគណៈកម្មការពិនិត្យលទ្ធកម្ម (Procurement Review Committee – PRC) គណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស (Consultant Evaluation Committee – CEC ) និងគណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនសាងសង់ (Bid Evaluation Committee – BEC) សម្រាប់គម្រោងលើកកម្រិតផ្លូវជាតិលេខ ៤៨ ពីចំណែកផ្លូវជាតិលេខ ៤ (ចំការហ្លួង) ដល់ ទីរួមខេត្តកោះកុង ក្រោមឥណទានសហប្រតិបត្តិការពីសាធារណរដ្ឋកូរ៉េ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន។
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់អោយប្រើប្រាស់នីតិវិធីរួម បច្ចុប្បន្នកម្ម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ពីដៃគូអភិវឌ្ឍន៍។
- យោងសេចក្តីសម្រេចលេខ ៣៥៤៦ សសរ.សក ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងជួររាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា។
- យោងកំណត់ហេតុកិច្ចពិភាក្សា ស្តីអំពីគម្រោងលើកកម្រិតផ្លូវជាតិលេខ ៤៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារ EDCF ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៤។
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

## សម្រេច

**ប្រការ១៖** កែសម្រួលគណៈកម្មការពិនិត្យលទ្ធកម្ម (Procurement Review Committee – PRC) គណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស (Consultant Evaluation Committee – CES) និងគណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនសាងសង់ (Bid Evaluation Committee – BEC) សម្រាប់គម្រោងលើកកម្រិតផ្លូវជាតិលេខ ៤៨ ពីបំបែកផ្លូវជាតិលេខ ៤ (ចំការហ្លួង) ដល់ទីរួមខេត្តកោះកុង ក្រោមឥណទានសហប្រតិបត្តិការពីសាធារណរដ្ឋកូរ៉េ ដែលមានសមាសភាពដូចខាងក្រោម៖

**ក. គណៈកម្មការ** PRC

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **តូច ចាន់កុសល** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **តំណាង** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-លោកជំទាវ | **ភុយ សុជានី** | អនុរដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-ឯកឧត្តម | **គី សុតាត់** | អគ្គនាយកសាធារណការ | សមាជិក |
| ៥- **តំណាង** អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្រ.ស.ហ.វ | | | សមាជិក |

-គណៈកម្មការ PRC មានភារកិច្ច៖

- ប្រកាសដេញថ្លៃ ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស និងក្រុមហ៊ុនសាងសង់
- ទំនាក់ទំនងជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងភាគី Export Import Bank of Korea
- ធ្វើវិចនាលទ្ធកម្ម និងឯកសារពាក់ព័ន្ធ ដែលគណៈកម្មការ CEC និង BEC បានរៀបចំ និងវាយតម្លៃ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃ និងលើកជាសំណូមពរជូន ឯកឧត្តម ទេសរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ពិនិត្យ និងសម្រេច។

**ខ. គណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស** (CEC) **និងគណៈកម្មការវាយ តម្លៃជ្រើសរើសក្រុមហ៊ុន សាងសង់** (BEC)៖

| | | | |
|---|---|---|---|
| ១-លោក | **ហេង រ័ត្នពិសិដ្ឋ** | ប្រធាននាយកដ្ឋានផ្លូវថ្នល់ | ប្រធាន |
| ២-**តំណាង** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | អនុប្រធាន |
| ៣-លោក | **ហឿន សំឡេង** | នាយខុទ្ទកាល័យ | សមាជិក |
| ៤-**តំណាង** អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | សមាជិក |
| ៥-លោក | **យូ ដារ៉ា** | អនុប្រធាននាយកដ្ឋាន ផ្លូវថ្នល់ | សមាជិក |
| ៦-លោក | **ហេង ចារ៉ា** | ប្រធានការិយាល័យ ហ.ថ.វ | សមាជិក |
| ៧-លោក | **ឈុំ សុខ** | អនុប្រធានការិ.នៃនាយកដ្ឋានផ្លូវថ្នល់ | សមាជិក |
| ៨-លោក | **ជា ដារ៉ា** | អនុប្រធានការិ.នៃនាយកដ្ឋានផ្លូវថ្នល់ | សមាជិក |
| ៩-លោក | **ហ៊ាង សុវណ្ណឫទ្ធិ** | មន្ត្រីខុទ្ទកាល័យ | សមាជិក |

- គណៈកម្មការនេះមានភារកិច្ច៖

- ពិនិត្យ សិក្សា និងវាយតម្លៃលើឯកសារបច្ចេកទេស និងហិរញ្ញវត្ថុ (Technical and Financial Proposals) របស់ក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស ដែលចូលរួមដេញថ្លៃ

- ពិនិត្យ សិក្សា និងវាយតម្លៃលើឯកសារបច្ចេកទេស និងហិរញ្ញវត្ថុ (Technical and Financial Proposals) របស់ក្រុមហ៊ុនសាងសង់ ដែលចូលរួមដេញថ្លៃ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃ សម្រាប់ដាក់ជូនគណៈកម្មការ PRC ដើម្បីធ្វើវិចនាលទ្ធកម្ម និងសម្រេចវិចនាលទ្ធកម្ម។

**<u>ប្រការ២៖</u>** សមាជិកគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**<u>ប្រការ៣៖</u>** រាល់ទំនាក់ទំនងរវាងភាគីកម្ពុជា និង Export Import Bank of Korea ត្រូវធ្វើឡើងតាមរយៈប្រធានគណៈកម្មការ PRC ។ រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានាភាករណ៍។

**<u>ប្រការ៤៖</u>** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ និងអង្គភាពពាក់ព័ន្ធព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**ស៊ុន ចាន់ថុល**

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យ ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារកាលប្បវត្តិ